ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧ សជណ

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១៣២ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៨

***បងប្អូនកម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ជាទីស្នេហា!***

តាងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ចូលរួមជាមួយបងប្អូនកម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ ក្នុងឱកាសនៃការប្រារព្ធខួបអនុស្សាវរីយ៍ លើកទី១៣២ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ក្រោមប្រធានបទ "**សន្តិភាព ស្ថិរភាព ដើម្បីការងារ និងមុខរបរ**"។

ព្រះរាជាណាចក្រកម្ពុជាយើង ទិវាពលកម្មអន្តរជាតិថ្ងៃទី១ ខែឧសភា ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំចាប់តាំងពីថ្ងៃរំដោះពីរបបប្រល័យពូជសាសន៍ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

ចំពោះរូបខ្ញុំផ្ទាល់ ជាច្រើនឆ្នាំកន្លងមកនេះ បានជួបសំណេះសំណាលជាមួយតំណាងកម្មករនិយោជិត និងបុគ្គលិកសិក្សា និងកម្មករនិយោជិតនៅកំពង់ផែខេត្តព្រះសីហនុ ក្នុងឱកាសអបអរសាទរទិវាពលកម្មអន្តរជាតិ ថ្ងៃទី១ ខែឧសភា។ ចាប់ពីចុងឆ្នាំ២០១៧ រហូតដល់បច្ចុប្បន្ន ខ្ញុំបានជួបសំណេះសំណាលសួរសុខទុក្ខជាមួយ ប្រធានរដ្ឋបាល ប្រធានផ្នែក ប្រធានក្រុម ជំនួយការ និងបងប្អូនកម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធ ប្រមាណជិត៥០ម៉ឺននាក់ និងបន្តជួបរហូតក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដើម្បីជំរុញការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និងដាក់ឲ្យអនុវត្តនូវគោលនយោបាយគាំពារសង្គមថ្មីៗផ្សេងទៀត។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនិងអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ និងទី៣ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា ដោយផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើកំណែទម្រង់លើគ្រប់វិស័យ និងបានដាក់ចេញនូវគោលនយោបាយថ្មីមួយចំនួនរួមមាន គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ, គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា, គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម។

សន្តិភាពនិងស្ថិរភាពនយោបាយ ត្រូវបានធានារឹងមាំដែលជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនថេរជាមធ្យមប្រចាំឆ្នាំ ៧%។ កម្ពុជាបានប្តូរពីប្រទេសដែលមាន

ចំណូលកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងកំពុងឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

១-ឆ្នាំ២០១៨ នេះ វិស័យការងារបន្តអភិវឌ្ឍរីកចម្រើន អត្រាមានការងារធ្វើ ៩៩,៣% បរិមាណការងារសរុបមានប្រមាណជិត ១០លាននាក់។ សហគ្រាស គ្រឹះស្ថាន សេដ្ឋកិច្ចក្នុងប្រព័ន្ធដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានចំនួនសរុបជាង១ម៉ឺន២ពាន់ គ្រឹះស្ថាន កើនចំនួន១០,០២% និងមានកម្មករនិយោជិតសរុបចំនួនជិត១លាន៥សែននាក់ កើនចំនួន ២១,១១% (ស្រីជាង៨សែននាក់) ធៀបនឹងឆ្នាំ២០១៧។ សហគ្រាស គ្រឹះស្ថានសេដ្ឋកិច្ចក្រៅប្រព័ន្ធសរុបមានចំនួនជិត៦សែន មានកម្មករចំនួនជាង២លាន៤សែននាក់ វិស័យកសិកម្មប្រមាណជាង៤លាននាក់ ពលករធ្វើការនៅក្រៅប្រទេសមានចំនួនប្រមាណ១លាន២សែននាក់ និងមន្ត្រីសាធារណៈចំនួនប្រមាណជាង៥សែននាក់។

២-ប្រព័ន្ធអធិការកិច្ចការងារត្រូវបានកែទម្រង់ ពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ធ្វើឱ្យលក្ខខណ្ឌការងារ និងការទំនាក់ទំនងវិជ្ជាជីវៈ កាន់តែមានភាពប្រសើរឡើង។ បញ្ហាកូដកម្ម បាតុកម្មត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព។ យន្តការត្រីភាគី ត្រូវបានពង្រឹងនិងបន្តនូវតួនាទីដ៏សំខាន់ក្នុងការដោះស្រាយបញ្ហានានាដែលទាក់ទងផលប្រយោជន៍របស់កម្មករនិយោជិត និងនិយោជក ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើងក្នុងឆ្នាំ២០១៨ បានកើនពីចំនួន១៥៣ដុល្លារអាមេរិក ទៅ១៧០ដុល្លារអាមេរិក កើន១១,១% បើគិតប្រាក់អត្ថប្រយោជន៍ផ្សេងៗទៀត កម្មករនិយោជិតម្នាក់ៗអាចទទួលបានប្រាក់ចំណូលពី១៨៧ ទៅ១៩៨ដុល្លារអាមេរិកក្នុងមួយខែ។ រាជរដ្ឋាភិបាលកំពុងរៀបចំច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ដើម្បីធានាការលើកកម្ពស់ជីវភាពរបស់កម្មករនិយោជិត។

៣-ការអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម បានផ្តល់អត្ថប្រយោជន៍ថ្មីៗជូនកម្មករនិយោជិត ដូចជា៖

- បានពិនិត្យ និងព្យាបាលជំងឺនៅតាមមន្ទីរពេទ្យរដ្ឋទាំងអស់ ដោយមិនបង់ប្រាក់
- បានអនុវត្តការផ្តល់ប្រាក់ឈ្នួល ១២០ភាគរយ និងការឈប់សម្រាករយៈពេល ៣ខែ ក្នុងពេលសម្រាលកូនជូនកម្មការិនី
- បានអនុវត្តកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មការិនីសម្រាលកូន ក្នុង១ខែ ជាមធ្យម ៤ ៨០០នាក់ ដោយផ្តល់ជូនកូន១នាក់ ថវិកាចំនួន៤០ម៉ឺនរៀល កូនភ្លោះ២នាក់ ថវិកាចំនួន៨០ម៉ឺនរៀល និងកូនភ្លោះ៣នាក់ ថវិកាចំនួន១លាន២សែនរៀល ព្រមទាំងទទួលបានថវិកាបន្ថែមចំនួន៥លានរៀល ពី **សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ផ្ទាល់
- រាជរដ្ឋាភិបាល បានកំណត់ឱ្យនិយោជកជាប់កាតព្វកិច្ចបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព១០០% ជំនួសកម្មករនិយោជិតចាប់ពីខែមករា ឆ្នាំ២០១៨
- រដ្ឋបាលថ្នាក់ក្រោមជាតិ បានត្រួតពិនិត្យជាប្រចាំនូវថ្លៃឈ្នួលផ្ទះ ថ្លៃទឹក និងថ្លៃអគ្គិសនី នៅតាមផ្ទះជួល និងបានផ្តល់ជូនកម្មករនិយោជិតធ្វើដំណើរតាមរថយន្តក្រុងនៅរាជធានីភ្នំពេញ ដោយឥតបង់ប្រាក់
- រាជរដ្ឋាភិបាលកំពុងរៀបចំដាក់ឲ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកសោធននិវត្តន៍ឆ្នាំ២០១៩

- រាជរដ្ឋាភិបាលបានផ្តល់បុរេប្រទានថវិកាចំនួនជាង៤លាន៦សែនដុល្លារ សម្រាប់ទូទាត់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតដែលរោងចក្របិទទ្វារដោយម្ចាស់រត់ចោល និង រៀបចំបទប្បញ្ញត្តិ ដើម្បីធានាអត្ថប្រយោជន៍របស់កម្មករនិយោជិតចំពោះករណីនេះនាពេលខាងមុខ
- រាជរដ្ឋាភិបាលកំពុងបន្តពង្រឹងកិច្ចសហការជាមួយប្រទេសជាដៃគូ ដើម្បីបន្តផ្តល់ឱកាសការងារ ជូនពលករ ការពារសិទ្ធិនិងផលប្រយោជន៍ពលករដែលកំពុងបម្រើការងារនៅប្រទេសទាំងនោះ បង្កលក្ខណៈសម្បត្តិឱ្យបងប្អូនទទួលបានរបបគាំពារសង្គម ទាំងបច្ចុប្បន្ន និងពេលដែលវិលត្រឡប់ មកវិញ។

***បងប្អូនកម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ជាទីស្នេហា !***

ជោគជ័យតាមចក្ខុវិស័យ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល គឺសុទ្ធតែមានការចូលរួមយ៉ាងសកម្ម និងសុឆន្ទៈពីសំណាក់អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត និងនិយោជក ក៏ដូចជាអង្គការអន្តរជាតិជាដៃគូផង ដែរ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់ក្រសួងស្ថាប័នពាក់ព័ន្ធនានា ជាពិសេសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានអនុវត្តដោយជោគជ័យនូវរាល់ភារកិច្ចខាងលើ។

ជាមួយគ្នានេះ ខ្ញុំសូមធ្វើការអំពាវនាវចំពោះ ក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ ក៏ដូចជា និយោជក កម្មករនិយោជិត សមាគមនិយោជក អង្គការសហជីព ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល និង អង្គការអន្តរជាតិពាក់ព័ន្ធទាំងអស់ សូមយកចិត្តទុកដាក់លើប្រការដូចខាងក្រោម៖

១-ត្រូវបន្តរក្សា និងពង្រឹងសន្តិភាព ស្ថិរភាព ដែលជាកត្តាគន្លឹះក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងការលើកកម្ពស់ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងកម្មករនិយោជិត។ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវបទបញ្ជា ០២.បប និង ០៣.បប របស់រាជរដ្ឋាភិបាល។

២-បន្តពង្រឹងយន្តការអធិការកិច្ចការងារឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាព លើកកម្ពស់ការយល់ ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចស្របច្បាប់របស់កម្មករនិយោជិត និងនិយោជក។ បន្តខិតខំលើកកម្ពស់លក្ខខណ្ឌ ការងារឱ្យកាន់តែប្រសើរឡើង ស្របតាមច្បាប់ស្តីពីការងារ។

៣-ត្រូវបន្តអនុវត្តអនុសាសន៍ទាំង ៩ចំណុច ដោយតាមដានការអនុវត្តប្រាក់ឈ្នួលអប្បបរមា ១៧០ ដុល្លារអាមេរិក កម្មករនិយោជិតទទួលការពិនិត្យព្យាបាលជំងឺដោយមិនបង់ប្រាក់ កម្មការិនីបានទទួល ប្រាក់ឈ្នួល ១២០ភាគរយ និងឈប់សម្រាករយៈពេល៣ខែ ក្នុងពេលសម្រាលកូន ការផ្តល់ប្រាក់ឧបត្ថម្ភ ដល់កម្មការិនីសម្រាលកូន កាតព្វកិច្ចរបស់និយោជកបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព១០០% ជំនួសកម្មករនិយោជិត ការត្រួតពិនិត្យជាប្រចាំនូវថ្លៃឈ្នួលផ្ទះ ថ្លៃទឹក និងថ្លៃអគ្គិសនី នៅតាមផ្ទះជួល និង កំពុងបន្តជំរុញការតភ្ជាប់បណ្តាញអគ្គិសនី និងទឹកស្អាតនៅតាមតំបន់ផ្ទះជួលរបស់កម្មករនិយោជិត ការដាក់ឱ្យ អនុវត្តរបបសន្តិសុខសង្គមផ្នែកសោធននិវត្តន៍ឆ្នាំ២០១៩ និងការដោះស្រាយបើកផ្តល់អត្ថប្រយោជន៍ផ្សេងៗ ជូន កម្មករនិយោជិត ដែលរោងចក្របិទទ្វារ។

៤-បន្តរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីការងារលើចំណុចមួយចំនួន ដើម្បីសម្រួលនីតិវិធីក្នុងការបើកផ្តល់ ប្រាក់អត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិត។ ជំរុញរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ច្បាប់ស្តីពីរបបសន្តិសុខសង្គម។

៥-បន្តអនុវត្តកម្មវិធីពិភាក្សាប្រាក់ឈ្នួលអប្បបរមាប្រចាំឆ្នាំ តាមរូបមន្ត និងយន្តការត្រីភាគីដែលគ្រប់ភាគីទទួលយកបានកន្លងមកក្នុងការកំណត់ការដំឡើងប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង។

៦-ត្រូវបន្តលើកទឹកចិត្តដល់មាតាបិតា អាណាព្យាបាល កម្មករនិយោជិត និងយុវជន ដើម្បីទទួលការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ជំនាញ ផលិតភាពការងារ និងមានសមត្ថភាពប្រកួតប្រជែង។

៧-បន្តពង្រឹងការអនុវត្តអនុសញ្ញាអន្តរជាតិខាងការងារដែលបានផ្តល់សច្ចាប័ន។ បន្តសហការជាមួយគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) គម្រោងបទដ្ឋានសង្គម និងការងារក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរនៅទ្វីបអាស៊ី (GIZ SLSG) នៅប្រទេសកម្ពុជា និងគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងជាសកល កម្មវិធីរួមគ្នារបស់អង្គការសហប្រជាជាតិ រួមគ្នាដើម្បីមុខរបរ និងការងារ របស់យុវជននៅកម្ពុជា- និងគម្រោងសហការជាមួយដៃគូអភិវឌ្ឍផ្សេងទៀត។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរជូនដល់បងប្អូនកម្មករនិយោជិត និងជនរួមជាតិដែលកំពុងធ្វើការទាំងក្នុង និងក្រៅប្រទេស ក៏ដូចជាអស់លោក លោកស្រី ជានិយោជក និងនិយោជិតបរទេសជាមន្ត្រីអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលកំពុងស្នាក់នៅ និងបំពេញភារកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា នូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ សុក្រ ៦ កើត ខែ ចេត្រ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**